**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ៖ បព ១៦ /២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃទស្សនកិច្ចផ្លូវការរបស់រដ្ឋមន្ត្រីការបរទេសនូវែលសេឡង់ នៅព្រះរាជាណាចក្រកម្ពុជា

តបតាមការអញ្ជើញរបស់ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា **ឯកឧត្តម វីនស្តុន ភីធឺរ** រដ្ឋមន្ត្រីការបរទេសនូវែលសេឡង់ បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី២៨ ដល់ ២៩ ខែវិច្ឆិកា ឆ្នាំ២០២៥។ ទស្សនកិច្ចនេះ បានបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរួមរបស់ប្រទេសទាំងពីរ ក្នុងការបន្តពង្រឹងទំនាក់ទំនងទ្វេភាគី និងស្វែងរកវិស័យថ្មីៗថែមទៀតសម្រាប់ធ្វើកិច្ចសហប្រតិបត្តិការ។ ក្នុងឱកាសទស្សនកិច្ចនេះ **ឯកឧត្តម វីនស្តុន ភីធឺរ** បានចូលជួបសំដែងការគួរសមចំពោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងបានជួបពិភាក្សាជាមួយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន**។

ក្នុងឱកាសនៃជំនួបសម្តែងការគួរសម នៅព្រឹកថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** និង**ឯកឧត្តម វីនស្តុន ភីធឺរ** បានសម្តែងការពេញចិត្តចំពោះទំនាក់ទំនងដ៏ល្អប្រសើរ រឹងមាំ និងយូរអង្វែងនៃប្រទេសទាំងពីរ ព្រមទាំងបានបញ្ជាក់ជាថ្មីពីការបន្តពង្រឹងមិត្តភាព និងកិច្ចសហ-ប្រតិបត្តិការ ដើម្បីសន្តិភាព វិបុលភាព និងការអភិវឌ្ឍប្រកបដោយចីរភាព នៃប្រទេសទាំងពីរ។

នៅព្រឹកថ្ងៃដដែលនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** និង**ឯកឧត្តម វីនស្តុន ភីធឺរ** បានជួបពិភាក្សាយ៉ាងស៊ីជម្រៅ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ដែលគ្របដណ្តប់លើវិស័យជាច្រើន។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរម្លឹកដោយអំណរគុណនូវការរួមចំណែករបស់ប្រទេសនូវែលសេឡង់ចំពោះដំណើរការស្វែងរកសន្តិភាព និងការស្តារកម្ពុជាឡើងវិញ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០ មក ជាពិសេសក្នុងកិច្ចខិតខំប្រឹងប្រែងបោសសម្អាតមីន និងការអភិវឌ្ឍធនធានមនុស្ស។ **ភាគីនូវែលសេឡង់** បានកោតសរសើរចំពោះការរីកចម្រើនយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា និងបានអះអាងជាថ្មីពីការប្តេជ្ញាចិត្តក្នុងការបន្តគាំទ្រដល់ការអភិវឌ្ឍរបស់កម្ពុជា។

ចំពោះកិច្ចសហប្រតិបត្តិការផ្នែកនយោបាយ **រដ្ឋមន្ត្រីការបរទេសទាំងពីរ** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការរក្សាការប្រាស្រ័យទាក់ទងគ្នាជាប្រចាំនៅគ្រប់កម្រិត ដើម្បីធ្វើឱ្យទំនាក់ទំនងនយោបាយកាន់តែស៊ីជម្រៅ និងរិះរកវិស័យថ្មីៗនៃកិច្ចសហប្រតិបត្តិការ។ **ភាគីទាំងពីរ** ក៏បានស្វាគមន៍ការរៀបចំ

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

កិច្ចពិគ្រោះយោបល់លើកទី៣ រវាងក្រសួងការបរទេសកម្ពុជា និងនូវែលសេឡង់ ដែលបានប្រព្រឹត្តទៅដោយជោគជ័យ កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៥ នៅទីក្រុងវែលីងតោន និងបានឯកភាពគ្នាបន្តជំរុញការប្រើប្រាស់យន្តការសន្ទនានយោបាយនេះឱ្យបានទៀងទាត់។

ចំពោះកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ ដោយទទួលស្គាល់ថា ឧក្រិដ្ឋកម្មឆ្លងដែន រួមទាំងការឆបោកតាមប្រព័ន្ធអនឡាញ គឺជាការគំរាមកំហែងដ៏ធ្ងន់ធ្ងរដល់សន្តិសុខជាតិ ដែលទាមទារឱ្យមានកិច្ចសហប្រតិបត្តិការក្នុងតំបន់ **រដ្ឋមន្ត្រីការបរទេសទាំងពីរ** បានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តយ៉ាងមោះមុតក្នុងការជំរុញកិច្ចសហប្រតិបត្តិការក្នុងវិស័យសន្តិសុខ និងបានឯកភាពធ្វើការរួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មទាំងនេះ។

ក្នុងវិស័យសេដ្ឋកិច្ច **រដ្ឋមន្ត្រីការបរទេសទាំងពីរ** បានឯកភាពគ្នាថា ស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងពីរ គួរតែបង្កើនកិច្ចខិតខំប្រឹងប្រែងប្រើប្រាស់ឱ្យអស់សក្តានុពលដែលមាន ដើម្បីលើកកម្ពស់ពាណិជ្ជកម្ម ជាពិសេស ក្នុងវិស័យកសិកម្ម បង្កើនវំហូរវិនិយោគ និងជំរុញការបំពេញបន្ថែមឱ្យគ្នាក្នុងវិស័យសេដ្ឋកិច្ច។

ការប្រាស្រ័យទាក់ទងរវាងប្រជាជននិងប្រជាជន នៅតែជាមូលដ្ឋានគ្រឹះនៃទំនាក់ទំនងទ្វេភាគី។ **រដ្ឋមន្ត្រីការបរទេសទាំងពីរ** បានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃវិស័យទេសចរណ៍ សម្រាប់ចូលរួមលើកកម្ពស់ការយល់ដឹងពីគ្នាទៅវិញទៅមក និងបង្កើនកំណើនសេដ្ឋកិច្ច។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះការផ្តល់ជំនួយដ៏យូរអង្វែងរបស់នូវែលសេឡង់ក្នុងការអភិវឌ្ឍធនធានមនុស្ស តាមរយៈកម្មវិធីបណ្តុះបណ្តាលរយៈពេលវែង និងខ្លី ដែលបាន និងកំពុងរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍមូលធនមនុស្សនៅកម្ពុជា។

ក្រៅពីកិច្ចពិភាក្សាទ្វេភាគី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជម្រាបជូន **ឯកឧត្តម វីនស្តុន ភីធឺរ** អំពីការវិវឌ្ឍថ្មីៗពាក់ព័ន្ធនឹងការអនុវត្តសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួរ ដែលបានចុះហត្ថលេខារវាងកម្ពុជា និងថៃ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ និងបានគូសបញ្ជាក់ថា កម្ពុជានឹងនៅតែប្តេជ្ញាអនុវត្តតាមខ្លឹមសារ នៃសេចក្តីថ្លែងការណ៍រួមនេះ។ **ភាគីទាំងពីរ** ក៏បានផ្លាស់ប្តូរទស្សនៈអំពីការវិវត្តក្នុងតំបន់ និងអន្តរជាតិ ដែលជាផលប្រយោជន៍រួម និងបានអះអាងជាថ្មីពីការប្តេជ្ញាចិត្តរួមគ្នាក្នុងការគាំទ្រផលប្រយោជន៍ទៅវិញទៅមក និងធ្វើការរួមគ្នាដើម្បីលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាព តាមរយៈកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ។

**ឯកឧត្តម វីនស្តុន ភីធឺរ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** ដែលបានផ្តល់កិច្ចស្វាគមន៍យ៉ាងកក់ក្តៅ និងបដិសណ្ឋារកិច្ចដ៏ល្អប្រសើរ សម្រាប់គណៈប្រតិភូនូវែលសេឡង់។ **ឯកឧត្តម វីនស្តុន ភីធឺរ** ក៏បានអញ្ជើញ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** ទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសនូវែលសេឡង់។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានឯកភាពទទួលយកការអញ្ជើញនេះដោយក្តីរីករាយ៕

ថ្ងៃសៅរ៍ ៩កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION
No. PR 66/2025 MFA.IC

PRESS RELEASE

## Outcomes of the Official Visit of the Foreign Minister of New Zealand to the Kingdom of Cambodia

At the invitation of **His Excellency PRAK Sokhonn**, Deputy Prime Minister, Minister of Foreign Affairs and International Cooperation of the Kingdom of Cambodia, the **Rt. Hon. Winston Peters**, Minister of Foreign Affairs of New Zealand, paid an official visit to the Kingdom of Cambodia from 28 to 29 November 2025. The visit reaffirmed the shared commitment of both countries to further strengthening bilateral ties and exploring new avenues for cooperation. During the visit, the **Rt. Hon. Winston Peters** paid a courtesy call on **Samdech Moha Borvor Thipadei HUN Manet**, Prime Minister of the Kingdom of Cambodia, and also met with **Deputy Prime Minister PRAK Sokhonn**.

During the courtesy call on the morning of 29 November 2025, **Samdech Thipadei Prime Minister** and the **Rt. Hon. Winston Peters** expressed satisfaction with the enduring excellent bilateral ties and reaffirmed their resolve to consolidate friendship and cooperation for peace, prosperity, and sustainable development of the two countries.

Later that morning, **Deputy Prime Minister PRAK Sokhonn** and the **Rt. Hon. Winston Peters** held comprehensive discussions aimed at advancing bilateral cooperation, across a wide range of sectors. **His Excellency the Deputy Prime Minister** recalled with high appreciation New Zealand's contribution to the peace process and post-conflict reconstruction of Cambodia since the early 1990s, particularly in mine-clearance efforts and human resource development. **The New Zealand side** praised Cambodia's rapid economic and social progress and reaffirmed its commitment to continuing support for Cambodia's development.

On political cooperation, the **two Foreign Ministers** emphasized the importance of maintaining regular engagements at all levels to deepen political ties and identify new areas of collaboration. They also welcomed the successful convening of the 3rd Foreign



Address : N° 3, Samdech HUN Sen Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh

Ministries' Consultations between Cambodia and New Zealand on 22 August 2025 in Wellington, and agreed to continue promoting this mechanism for regular dialogue.

On security, recognizing transnational crimes, including online scams, as a serious threat to national security that requires regional cooperation, **the two Ministers** reaffirmed their strong commitment to advancing security cooperation and agreed to work together to combat these crimes.

In the economic sphere, **the Ministers** agreed that the relevant institutions of both countries should intensify efforts to capitalize on untapped potentials in order to increase trade, particularly in agriculture, enhance investment flow, and foster economic complementarity.

People-to-people exchanges remain a cornerstone of relations. **The Ministers** emphasized the importance of tourism for mutual understanding and economic growth. **His Excellency the Deputy Prime Minister** expressed his appreciation for New Zealand's longstanding assistance in human resource development through both long-term and short-term training programs, which have contributed meaningfully to the development of Cambodian human capital.

Beyond bilateral matters, **His Excellency the Deputy Prime Minister** briefed the **Rt. Hon. Winston Peters** on recent developments regarding the implementation of the Kuala Lumpur Joint Declaration signed between Cambodia and Thailand on 26 October 2025. He underscored Cambodia's steadfast commitment to fully carrying out its obligations under the agreement. **Both sides** also exchanged views on regional and international developments of common interest, and reaffirmed their mutual commitment to supporting each other's core interests and to working together to promote peace, stability, and prosperity through cooperation in international fora.

The **Rt. Hon. Winston Peters** expressed deep appreciation to **Deputy Prime Minister PRAK Sokhonn** for the warm welcome and excellent arrangements extended to the New Zealand delegation. He also extended a cordial invitation to **Deputy Prime Minister PRAK Sokhonn** to undertake an official visit to New Zealand, which the **Deputy Prime Minister** graciously accepted.

Phnom Penh, 29 November 2025